ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៨២

ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

**សាលដីកា**

លេខ ១៧៤ "III"

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣៧៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោក[redacted]ធារី, លោក [redacted]ចាន់ដារ៉ា និងលោក[redacted]ន្ទសីហា ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន ក្នុងការប្តឹងសាទុក្ខ, បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោកស្រី[redacted] កនិកា ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted]ដារ៉ា ក្នុងការប្តឹងសាទុក្ខ, បណ្តឹងសាទុក្ខលេខ ៣៨៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]យ៉ន, បណ្តឹងសាទុក្ខលេខ ៤០២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ច័ន្ទភារុធ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ[redacted] រតនា ក្នុងការប្តឹងសាទុក្ខ ប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII "ណ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖



Scanned with CamScanner

**បុគ្គលប្តឹងសាទុក្ខ ៖**

១-ឈ្មោះ [redacted] **ដារ៉ា** ភេទប្រុស អាយុ ២១ ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងញៀន មានកន្លែងកំណើតនៅឃុំព្រែកលួង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានលំនៅមុន[redacted] លំ ឃុំព្រែកលួង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោ[redacted] ម្តាយឈ្មោះ [redacted] នៅ “រ” លីវ ។ ទោសពីមុនគ្មាន ។

-ឃាត់ខ្លួន ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ តាមដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៣៤៧ “ភ” ដ.ព.ស ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០, ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨៩១ “ភ” ដ.ឃ.ដ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០, ដីកាសម្រេចពន្យារពេលឃុំខ្លួនបណ្តោះអាសន្នលេខ ៤៧២៥ “ហ” ដ.ព.ស ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងដីកាបង្គាប់ឱ្យពន្យារពេលឃុំខ្លួនបណ្តោះអាសន្នលេខ ៧២៤១“ហ” ដ.ឃ.ដ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-លោកស្រី [redacted] កនិកា ជាមេធាវីការពារសិទ្ធិ។

២-ឈ្មោះ [redacted] **ថាវរិន** ហៅ **ទូច** ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមេការ មានកន្លែងកំណើតនៅឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ មានលំនៅសព្វថ្ងៃ[redacted] បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ[redacted]“រ” ។ ទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៧១៦ “ណ” ដ.ច.ន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ (ម១) ។

-លោក [redacted] ធារី , លោក [redacted] ចាន់ដារ៉ា និងលោក [redacted] ច័ន្ទសីហា ជាមេធាវីការពារ ។

៣-ឈ្មោះ [redacted] **រតនា** ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មានកន្លែងកំណើតនៅឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ មានលំនៅសព្វថ្ងៃនៅភូមិបារាយណ៍ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ ។

-មានដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ១៧១៥ “ណ” ដ.ច.ន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ (ម១) ។

-លោក[redacted]ន្ទតារាវុធ ជាមេធាវីការពារ ។

**ជាប់ចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្កាយ) ផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោ[redacted] **យ៉ន** ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ មុខរបរបើកបររថយន្ត មានកន្លែងកំណើតនៅភូមិចុងកាល់ ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ មានលំនៅឋានមុនពេលឃុំខ្លួនស្នាក់នៅផ្ទះគ្មានលេ[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ[redacted]“រ” ប្រពន្ធឈ្មោះ [redacted]“រ” មានកូន ០២ នាក់ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៨៩០ “ភ” ដ.ឃ.ដ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

-លោក [redacted] បូរ៉ា ជាមេធាវីការពារ ។

**ជាប់ចោទពីបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ក្លឹបកំសាន្ត FLY ផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**បុគ្គលពាក់ព័ន្ធ៖**

៥-ឈ្មោះ [redacted] **ធារី** ភេទស្រី អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរមេការ ទីកន្លែងកំណើត នៅភូមិព្រៃផ្តាក់ ខេត្តស្វាយរៀង មានលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល [redacted] ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] មានកូន ០៣ នាក់ ។ ទោសពីមុនគ្មាន ។

៦-ឈ្មោះ [redacted] **ធីតា** ភេទស្រី អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ។

៧-ឈ្មោះ [redacted] **លីថេង** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ។

៨-ឈ្មោះ [redacted] **សុនីន** ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ។

**<u>អំពីអង្គហេតុ៖</u>**

មុនពេលកើតហេតុនោះ ឈ្មោះ [redacted] ថាវរិន បានបើកក្លឹបកំសាន្តឈ្មោះ FLY "ផ្លាយ" (ចំណុចកើតហេតុ) ដើម្បីឱ្យជនរងគ្រោះដែលមកលេងក្នុងក្លឹបកំសាន្តអាចទិញគ្រឿងញៀនយកទៅប្រើប្រាស់បាន តាមរយៈបក្ខពួករបស់ឈ្មោះ [redacted] ដារ៉ា ,ឈ្មោះ [redacted]រតនា ,ឈ្មោះ ថៃ និងឈ្មោះ ឡុង ដែលបានរៀបចំទុករួចជាស្រេច និងមានការសម្រួលពីបុគ្គលិកនៅក្នុងក្លឹបកំសាន្តនោះឈ្មោះ [redacted] ធារី ,ឈ្មោះ [redacted] យ៉ន ,ឈ្មោះ [redacted] ធីតា ,ឈ្មោះ [redacted] លីថេង ,ឈ្មោះ [redacted] សុនីន និងឈ្មោះ រ៉ា ។

លុះដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ៣០ នាទី យប់ កម្លាំងនគរបាលនៃការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល បានសហការជាមួយកម្លាំងនគរបាលអន្តរាគមន៍កងពិសេសនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះទៅបង្ក្រាបទីតាំងខាងលើ និងចាប់យកវត្ថុតាង គឺ ៖

ដកហូតពីជនល្មើសឈ្មោះ [redacted] ដារ៉ា មានដូចខាងក្រោម៖

-ម្សៅក្រាមពណ៌សថ្លាចំនួន ១០១ កញ្ចប់ សរុបទម្ងន់ ២៤,៣៥ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទកេតាមីន ។

-ថ្នាំគ្រាប់ពណ៌ស្វែចំនួន ៣២ គ្រាប់ សរុបទម្ងន់ ១២,០៧ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទអឹមដេអឹមអា និងមេតំហ្វេតាមីន ។

-ថ្នាំគ្រាប់ពណ៌ត្រួយចេកចំនួន ១០ គ្រាប់ សរុបទម្ងន់ ៤,៣៨ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទអឹមដេអឹមអា ។

ដកហូតពីជនជាប់ចោទឈ្មោះ [redacted] ធារី មានដូចខាងក្រោម៖

-ម្សៅម៉ដ្ឋពណ៌សចំនួន ៣៥ កញ្ចប់ សរុបទម្ងន់ ៧,៩៦ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ កេតាមីន ។

Scanned with CamScanner

-ថ្នាំគ្រាប់ពណ៌ស្វៃចំនួន ១២ គ្រាប់ សរុបទម្ងន់ ៤,៥៨ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា និងមេតំហ្វេតាមីន ។

-ថ្នាំគ្រាប់ពណ៌ត្រួយចេកចំនួន ០៧ គ្រាប់ សរុបទម្ងន់ ២,៥៩ ក្រាម លទ្ធផលកោសលវិច័យជាប្រភេទ អឹមដេអឹមអា ។

បន្ទាប់មកសមត្ថកិច្ចបាននាំខ្លួនជនល្មើសឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ធារី រួមទាំងបក្ខពួកឈ្មោះ [redacted] យ៉ន ,ឈ្មោះ [redacted] ធីតា ,ឈ្មោះ [redacted] លីថេង និងឈ្មោះ [redacted] សុនីន ព្រមទាំងភស្តុតាងដែលពាក់ព័ន្ធទាំងអស់ បញ្ជូនទៅការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញដើម្បីចាត់ការតាមនីតិវិធីច្បាប់។ ចំណែកមេក្លោងជួញដូរគ្រឿងញៀននិងបក្សពួកផ្សេងទៀតបានរត់គេចខ្លួន ។

-បានឃើញ សាលក្រមលេខ ១៤០៣ "ណក្រ៦" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ឱ្យជនជាប់ចោទ៖

ក.ឈ្មោះ [redacted] លីថេង ភេទប្រុស អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ ។

ខ.ឈ្មោះ [redacted] សុនីន ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ ។

គ.ឈ្មោះ [redacted] ធីតា ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ ។

រួចខ្លួនពីបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ , មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោសជនជាប់ចោទ ៖

ក-ឈ្មោះ [redacted] ចាវរិន ហៅ ទូច ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ។

ខ-ឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៧ (ប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ។

គ-ឈ្មោះ [redacted] ដារ៉ា ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ ។

ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្លឹបកំសាន្ត FLY (ផ្លាយ) ផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១១ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ឃ-ឈ្មោះ [redacted] ធារី ភេទស្រី អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ ។

ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

ង-ឈ្មោះ [redacted] យ៉ន ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ ។

ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។



Scanned with CamScanner

ពីបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ក្លឹបកំសាន្ត FLY ផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ២៩ នៃព្រហ្មទណ្ឌ និងមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-បង្គាប់ឱ្យសមត្ថកិច្ចចាប់-ឃុំខ្លួនឈ្មោះ [redacted]ថាវរិន ហៅ ទូច ភេទប្រុស អាយុ ៣៥ ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ[redacted]តនា ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ មកដាក់ពន្ធនាគារតាមអំណាចសាលក្រមនេះ ។

៤-វត្ថុចាប់យកក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៥០៨ រ.វ.ត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក-ម៉ូតូម៉ាក ឃ្យូប៊ិច ពណ៌ខៀវ ពាក់ស្លាកលេខ ភ្នំពេញ ១HT-២៩៧៦ ។

ខ-ទូរស័ព្ទដៃចំនួន ០១ (មួយ) គ្រឿង ម៉ាកអាយហ្វូន ពណ៌ទឹកមាស ។

គ-ទូរស័ព្ទដៃចំនួន០១(មួយ)គ្រឿងម៉ាក អាយហ្វូន ពណ៌ទឹកប្រាក់ ។

សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-វត្ថុចាប់យកក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ៩០៨ រ.វ.ត ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន ៖

៥-១-ស្រោមសំបុត្របិទជិតពណ៌លឿងចំនួន០១(មួយ) ដែលមានសរសេរថា ៖

ក-ម្សៅម៉ដ្ឋពណ៌សថ្លាចេញពណ៌ស្វាយ សង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទកាតាមីន ទម្ងន់ ៧,៩៦ (ប្រាំពីរកណ្តក់សញ្ញាកៅសិបប្រាំមួយ) ក្រាម ។

ខ-ថ្នាំក្រាមពណ៌ស្លែចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទ អ៊ិចស្តាស៊ី ទម្ងន់ ៤,៥៨ (បួនកណ្តក់សញ្ញាហាសិបប្រាំបី)ក្រាម ។

គ-ថ្នាំក្រាមពណ៌ត្រួយចេកចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀន ប្រភេទអ៊ិចស្តាស៊ី ទម្ងន់ ២,៥៩(ពីរកណ្តក់សញ្ញាហាសិបប្រាំបួន)ក្រាម ។

ឃ-ដបពណ៌ខ្មៅមានទឹក ពុំបានដកធ្វើតេស្ត និងសំបកថង់ប្លាស្ទិកចំនួន ៣៧ (សាមសិបប្រាំពីរ) ដោយមានស្នាមផ្តិតមេដៃរបស់ឈ្មោះ[redacted]រី និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។

៥-២-ស្រោមសំបុត្របិទជិតពណ៌លឿងចំនួន ០១ (មួយ) ដែលមានសរសេរថា ៖

ក-ដុំក្រាមពណ៌សថ្លាចេញពណ៌ស្វាយ សង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់ ២៤,៣៥(ម្ភៃបួនកណ្តក់សញ្ញាសាមសិបប្រាំ)ក្រាម ។

ខ-ថ្នាំគ្រាប់ពណ៌សចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទអ៊ិចស្តាស៊ី ទម្ងន់ ១២,០៧ (ដប់ពីកណ្តក់សញ្ញាសូន្យប្រាំពីរ)ក្រាម ។

គ-ថ្នាំគ្រប់ពណ៌ត្រួយចេកចេញពណ៌ប្រផេះ សង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទ អ៊ិចស្តាស៊ី ទម្ងន់ ៤,៣៨ (បួនកណ្តាក់សញ្ញាសាមសិបប្រាំបី)ក្រាម និងសំបកថង់ប្លាស្ទិកចំនួន ១០៥ (មួយរយប្រាំ) ដោយមានស្នាមផ្តិតមេដៃរបស់ឈ្មោះ[redacted]រ៉ា និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ។



Scanned with CamScanner

៥-៣-ម៉ូតូម៉ាកហុងដាស្កុបពី ពណ៌សលាយព្រីងទុំ ពាក់ស្លាកលេខ ភ្នំពេញ ១BB-១០៨០ ចំនួន០១(មួយ) គ្រឿង (មិនប្រក្រតី) ។

៥-៤-រថយន្តម៉ាក តូយូតាព្រីស ពណ៌ខៀវ ពាក់ស្លាកលេខ ភ្នំពេញ ២AR-២៨៨៤ ចំនួន០១(មួយ)គ្រឿង (មិនប្រក្រតី) ។

៥-៥-ទូរស័ព្ទដៃម៉ាក Huawei ពណ៌ខ្មៅ ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៥-៦-ទូរស័ព្ទដៃម៉ាក Iphone ពណ៌ទឹកប្រាក់ ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៥-៧-ទូរស័ព្ទដៃម៉ាក Oppo ពណ៌ទឹកប៊ិច ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៥-៨-ទូរស័ព្ទដៃ ម៉ាក Huawel ពណ៌ទឹកសមុទ្រ ចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៥-៩-ប្រាក់ដុល្លារចំនួន៥៧០(ប្រាំរយចិត្តសិប)ដុល្លារអាមេរិក ។

៥-១០-ប្រាក់ដុល្លារចំនួន១៧០(មួយរយចិត្តសិប)ដុល្លារអាមេរិក ។

៥-១១-ប្រាក់រៀលចំនួន១.២០០.០០០(មួយលានពីររយពាន់)រៀល ។

៥-១២-ប្រាក់រៀលចំនួន១.២០០.០០០(មួយលានពីររយពាន់)រៀល ។

៥-១៣-ជញ្ជីងថ្លឹងគ្រឿងញៀនចំនួន០១(មួយ) (មិនដំណើរការ) ។

៥-១៤-ឧបករណ៍ជក់គ្រឿងញៀនចំនួន០១(មួយ) ។

៥-១៥-ម៉ូនីទ័រចំនួន០១(មួយ)គ្រឿង (មិនដំណើរការ) ។

៥-១៦-CPU ម៉ាកខែល ចំនួន០១(មួយ) (មិនដំណើរការ) ។

៥-១៧-ម៉ាស៊ីនម៉ាក EPSON ចំនួន០១(មួយ) (មិនដំណើរការ) ។

៥-១៨-ម៉ាស៊ីនព្រីនវិក័យប័ត្រចំនួន០២(ពីរ)គ្រឿង(មិនដំណើរការ) ។

៥-១៩-អាយកូមម៉ាក TYT ពណ៌ខ្មៅ ចំនួន០៥(ប្រាំ) ។

៥-២០-ឯកសារពាក់ព័ន្ធមួយចំនួន ។

សម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-ទីតាំងដីឡូតិ៍និងអគារ ស្ថិតនៅផ្លូវកែវចិន្តា ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដែលមានកិច្ចសន្យាស្តីពីការជួលទីតាំងដីឡូតិ៍និងអគារ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ធ្វើឡើងរវាងលោកជំទាវឧកញ៉ា [redacted] វុទ្ធី និងឈ្មោះ [redacted] ថាវរិន ដែលមានចុះហត្ថលេខា និងប្រថាប់ត្រាដោយមេធាវី [redacted] វណ្ណយ និងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១១០៦០៣-១៤៨០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

សម្រេចប្រគល់ឲ្យទៅម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា៩៤ កថាខណ្ឌ៣ និងមាត្រា៩៦ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាំ, ឈ្មោះ [redacted] ធារី, ឈ្មោះ [redacted] យ៉ន, ឈ្មោះ[redacted] ធីតា, ឈ្មោ[redacted]បីផេង, ឈ្មោ[redacted]សុនីន, មេធាវី [redacted] ហៃ, មេធាវី[redacted] ផានី, មេធាវី [redacted]ពីស្វតី, មេធាវី [redacted] វី, មេធា[redacted] ផានិត, មេធា[redacted]កនិកា, មេធាវី [redacted]ណារី, មេធាវី [redacted]ស៊ុលវីយោ, មេធា[redacted] ពៅដារ៉ា, មេធា[redacted] ឡាង និងមេធ[redacted]ឌី កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ថាវរិន ហៅ ទូច និងឈ្មោះ [redacted] រតនា និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ។

គូភាគីមានសិទ្ធិប្ដឹងទាស់និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០០៨ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២ របស់ជនជាប់ចោទឈ្មោ[redacted]យ៉ន ក្នុងការប្ដឹងឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណក្រ៦” ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៣៣ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់លោកស្រី[redacted]កនិកា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ក្នុងការប្ដឹងឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណក្រ៦” ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៥៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ក្នុងការប្ដឹងឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណក្រ៦” ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៦៤ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់លោ[redacted]ស៊ីលវីយោ និងលោក[redacted] ដារ៉ា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted] ថាវរិន ក្នុងការប្ដឹងឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណក្រ៦” ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៦២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់លោក[redacted]ច័ន្ទសីហា និងលោក[redacted]ធារី ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted]ថាវរិន, [redacted] រតនា [redacted] យ៉ន ក្នុងការប្ដឹងឧទ្ធរណ៍ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណក្រ៦” ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII “ណ” ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-បដិសេធពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០០៨ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] យ៉ន, ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៣៣ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ របស់មេធា[redacted]កនិកា ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ[redacted]ដារ៉ា, ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ០៥៨ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់



Scanned with CamScanner

ជនជាប់ចោទឈ្មោះ[redacted]ដារ៉ា, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦៤ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់មេធាវី [redacted] ស៊ីលវីយោ និងមេធាវី [redacted] ពៅដារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]ថាវរិន និង ពាក្យបណ្តឹងឧទ្ធរណ៍លេខ ០៦២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់មេធា[redacted] ច័ន្ទសីហា និងមេធាវី [redacted]ាន់ដារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ថាវរិន ឈ្មោ[redacted]រតនា ឈ្មោះ[redacted]យ៉ន និង ឈ្មោ[redacted]ធារី ចោលជាអសារបង់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ “ណ” ក្រ៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]ដារ៉ា ឈ្មោះ[redacted]ធារី និងឈ្មោ[redacted]យ៉ន តាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ដារ៉ា ,ឈ្មោះ [redacted]ធារី និងឈ្មោះ [redacted]យ៉ន កំបាំងមុខជនជាប់ចោទឈ្មោ[redacted] ថាវរិន និងឈ្មោះ [redacted]តនា និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ដារ៉ា ឈ្មោះ[redacted]ារី និងឈ្មោ[redacted]យ៉ន កំបាំងមុខជនជាប់ចោទឈ្មោ[redacted]ថាវរិន និងឈ្មោះ[redacted]រតនា ទុកសិទ្ធិឱ្យប្តឹងទាស់និងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៨៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]យ៉ន ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII “ណ” ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤០២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់លោក[redacted]ច័ន្ទតារាវុធ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] រតនា ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII “ណ” ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៧៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោ[redacted]ធារី, លោក [redacted]ចាន់ដារ៉ា និងលោក [redacted]ច័ន្ទសីហា ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII “ណ” ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោក[redacted]កនិកា ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII “ណ” ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ របស់លោក[redacted]ច័ន្ទតារាវុធ ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ[redacted]តនា ។



Scanned with CamScanner

-បានឃើញ សារណាការពារ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់លោក[redacted] ធារី ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted]ថាវរិន ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោ[redacted] យ៉ន ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]ដាវ៉ា ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្ដីរាយការណ៍ ។

-សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទឈ្មោ[redacted]ដាវ៉ា, [redacted]យ៉ន, [redacted] ធារី និង [redacted] ថាវរិន ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះគឺត្រឹមត្រូវហើយ ដូចមានសំអាងហេតុត្រង់ចំណុចទី២,៣,៤,៥,៦ និង៧ ស្រាប់ ។ បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ[redacted] យ៉ន,[redacted]រតនា,[redacted] ដាវ៉ា និងឈ្មោះ [redacted]ថាវរិន ពុំមានមូលហេតុណាមួយដូចបញ្ញត្តនៅក្នុងមាត្រ ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ គប្បីបដិសេធចោល។ តំណាងមហាអយ្យការសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។

-លោកស្រី[redacted]កន្និកា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted]ដាវ៉ា បានធ្វើសេចក្ដីសន្និដ្ឋានថា ពាក់ព័ន្ធនឹងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ គឺកូនក្ដីខ្លួនមិនសុខចិត្តនឹងការសម្រេចសេចក្ដីដែលតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញពាក់ព័ន្ធនឹងការផ្ដន្ទាទោស ដែលសាលាឧទ្ធរណ៍ភ្នំពេញមិនបានពិនិត្យ និងពិចារណាតាមការស្នើសុំរបស់កូនក្ដីខ្លួនអំពីការបន្ធូរបន្ថយទោស ត្រង់មាត្រា៩៣ , មាត្រា៩៤ នៃនីតិវិធីក្រមព្រហ្មទណ្ឌ ។ ត្រង់ចំណុចនេះថ្វីត្បិតតែកូនក្ដីខ្លួនបានប្រព្រឹត្តបទល្មើសជាប់ពាក់ព័ន្ធនឹងគ្រឿងញៀននៅក្លឹបផ្កាយមែន តែនៅមុនថ្ងៃចាប់ខ្លួន គឺកូនក្ដីខ្លួនទើបតែចូលបម្រើការងារបានត្រឹមតែ៤ថ្ងៃនោះទេ ហើយនៅពេលចូលធ្វើការគឺខាងមេកាជាអ្នកណែនាំឱ្យធ្វើការដូចជាឈ្មោ[redacted] យ៉ន និងឈ្មោ[redacted]ធារី ដែលណែនាំឱ្យចូលបម្រើការដោយប្រើពាក្យថា យករីវ៉ាន់ឱ្យភ្ញៀវ គឺសំដៅយកគ្រឿងញៀនដែលភ្ញៀវត្រូវការ ។ ដូចនេះ រាល់ពេលភ្ញៀវកុម្មង់អីវ៉ាន់ គឺកូនក្ដីខ្លួនបានទៅយកគ្រឿងញៀនពីឈ្មោះ[redacted]ារី និងឈ្មោះ [redacted] យ៉ន ។ ចំពោះការរក្សាទុកគ្រឿងញៀននិងការចាត់ចែងគ្រឿងញៀន គឺស្ថិតនៅលើការចាត់ចែងរបស់ឈ្មោ[redacted]ធារី និងឈ្មោះ[redacted] យ៉ន ។ ចំពោះទីតាំងនិងរក្សាទុកគ្រឿងញៀន កូនក្ដីខ្លួនពុំបានដឹងនោះទេ ។ ចំណុចមួយទៀត នៅពេលយកគ្រឿងញៀន គឺយកបានម្ដងតែចំនួន០១ កញ្ចប់ប៉ុណ្ណោះ ក្នុងមួយកញ្ចប់លក់បានតែ ៧ (ប្រាំពីរម៉ឺន)រៀល នៅពេលដែលយកឱ្យភ្ញៀវតម្លៃ ៧៥.០០០ (ប្រាំពីរម៉ឺនប្រាំពាន់) រៀល ដូច្នេះកូនក្ដីខ្លួនចំណេញក្នុងមួយកញ្ចប់ត្រឹមតែ៥ (ប្រាំពាន់) រៀល ។ ពាក់ព័ន្ធនឹងចំណុចនេះ ដោយសារតែកូនក្ដីខ្លួនចង់បានលុយក្រៅម៉ោងនិងដើម្បីផ្គត់ផ្គង់ការសិក្សារៀនសូត្រ ពីព្រោះពេលថ្ងៃកូនក្ដីខ្លួនរៀនបរិញ្ញាបត្រឆ្នាំទី២ ហើយចំពោះការឆែកឆេរកូនក្ដីខ្លួនគ្មានផ្ទុកសារធាតុញៀនទេ ។ ចំណុចចុងក្រោយ កូនក្ដីខ្លួនបានសហការជាមួយមន្ត្រីនគរបាល និងមន្ត្រីគ្រប់ថ្នាក់បន្ថែមអំពី[illegible]



Scanned with CamScanner

ពិត ព្រមទាំងបានសារភាពកំហុសថា ខ្លួនគាត់ពិតបានជួញដូរគ្រឿងញៀនមែន ប៉ុន្តែមិនបានទទួលស្គាល់ថាគ្រឿងញៀននោះជារបស់ខ្លួនទេ ។ កូនក្តីខ្លួនបានស្នើសុំបន្ធូរបន្ថយទោសតាំងពីនៅសាលាដំបូងភ្នំពេញពុំបានពិចារណាផ្តល់ស្ថានសម្រាលដល់រូបខ្លួន ។ ហេតុដូចនេះ ក្នុងនាមខ្លួនជាមេធាវី សូមឱ្យប្រធានអង្គជំនុំជម្រះមេត្តាពិនិត្យនិងពិចារណា ដើម្បីផ្តល់ស្ថានសម្រាលត្រង់មាត្រា ៩៣, មាត្រា ៩៤ ដើម្បីឱ្យកូនក្តីខ្លួនបានឆាប់វិលត្រឡប់ទៅផ្ទះវិញ ដោយហេតុថា កូនក្តីខ្លួនជានិស្សិត បានត្រឡប់ទៅរៀនសូត្រវិញ និងមានម្តាយចាស់ជរាដែលត្រូវទៅមើលថែ ។

សំណូមពរ៖ សូមឱ្យតុលាការសម្រេចអំពីការផ្តន្ទាទោសឱ្យមានលក្ខណអប្បបរមាតាមមាត្រា ៤៨ នៃច្បាប់ស្តីពីគ្រឿងញៀន គឺចន្លោះនៃការផ្តន្ទាទោស ចាប់ពី ៥ ឆ្នាំដល់ ១០ ឆ្នាំ ប៉ុន្តែសាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសកូនក្តីខ្លួន ៦ (ប្រាំមួយ) ឆ្នាំ ដូច្នេះសូមស្នើសុំត្រឹមអប្បបរមា ។

-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានឆ្លើយថា ខ្លួនសូមឯកភាពតាមមេធាវីការពាររបស់ខ្លួន ។

-លោក[redacted]ធារី ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]ារវិន បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានប្តឹងសាទុក្ខមកតុលាការកំពូល ព្រោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសាលាឧទ្ធរណ៍ពុំបានពិចារណាលើកិច្ចសន្យាជួលទីតាំងរវាងកូនក្តីខ្លួនដែលជួលបន្តឱ្យឈ្មោះ [redacted] រតនា ។ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ៣០ នាទី អធ្រាត្រ កម្លាំងនគរបាលបានចុះបង្ក្រាបក្លឹបកំសាន្តផ្តាយ ដោយចាប់បានគ្រឿងញៀន បើយោងលើអង្គច្បាប់ កូនក្តីខ្លួនអស់សិទ្ធិជាម្ចាស់ក្លឹបកម្សាន្តផ្តាយតាំងពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ រាល់សកម្មភាពបើកក្លឹបកម្សាន្ត គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក [redacted] រតនា ដែលជាអ្នកជួលបន្ត ។

-លោក [redacted] ច័ន្ទតារាវុធ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ[redacted] រតនា បានធ្វើសេចក្តីសន្និដ្ឋានថា មូលហេតុដែលកូនក្តីខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល ព្រោះកូនក្តីខ្លួនមិនសុខចិត្តនឹងការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ភ្នំពេញដែលចោទប្រកាន់មកលើកូនក្តីខ្លួន ដោយចោទប្រកាន់ផ្អែកតែលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌តែមួយគត់ ដែលក្នុងរបាយការណ៍នោះ តាំងពីមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចមិនអាចកំណត់ឈ្មោះថា កូនក្តីខ្លួនឈ្មោះ[redacted] រតនា ទេ នៅក្នុងសំណុំរឿង ។ នៅក្នុងរបាយការណ៍នោះប្រហែលឈ្មោះ រតនា អាយុប្រហែល ២១ ឆ្នាំ ដោយសារតែមានចម្លើយសារភាពរបស់ឈ្មោះ[redacted]ធារី និងឈ្មោះ[redacted] យ៉ន ។ រហូតដល់សវនាការនៅសាលាដំបូងភ្នំពេញនិងសាលាឧទ្ធរណ៍ភ្នំពេញ សួរថា ស្គាល់ឈ្មោះកូនក្តីខ្លួនដែរឬទេ? ឈ្មោះ [redacted]ធារី និងឈ្មោះ[redacted]យ៉ន ឆ្លើយថាមិនស្គាល់ទេ មិនដែលលឺឈ្មោះនេះទេ ។ នៅក្នុងចម្លើយសារភាពរបស់អ្នកទាំងពីរនៅសមត្ថកិច្ច អ្នកទាំងពីរនេះបានឆ្លើយថា ជាការឆ្លើយទាំងបង្ខិតបង្ខំ ។ ទាក់ទងនឹងកិច្ចសន្យាជួលទីតាំងតពីឈ្មោះ [redacted] ថាវរិន គឺកូនក្តីខ្លួនមិនបដិសេធឡើយ ប៉ុន្តែចំពោះការគ្រប់គ្រងក្លឹបនិងចំណូលចំណាយ គឺពឹងលើបុគ្គលិកនៅទីនោះឈ្មោះ [redacted]យ៉ន ។ ចំពោះនៅថ្ងៃចុះបង្ក្រាបគឺកូនក្តីខ្លួនមិនបានស្ថិតនៅទីតាំងនោះទេ ។ ចំពោះរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺប្រហែលមានការភាន់ច្រឡំ ត្រង់



Scanned with CamScanner

សរសេរថា [redacted]ធារី ជាមេការ ហើយទទួលបានប្រាក់ខែចំនួន ៦០០ដុល្លារអាមេរិក ប៉ុន្តែនៅពេលសវនាការរបស់សាលាឧទ្ធរណ៍ខ្លួនបានសួរទៅឈ្មោះ [redacted]ធារី បានឆ្លើយថា ខ្លួនមិនមែនជាមេការទេ គឺជាអ្នកគិតលុយ ទទួលបានប្រាក់ខែតែ ២០០ ដុល្លារតែប៉ុណ្ណោះ ធ្វើការបណ្តោះអាសន្ន ទម្រាំគេរើសមេការថ្មីបាន ។ ចំពោះរបាយការណ៍នេះមិនស៊ីសង្វាក់គ្នាទាល់តែសោះ ។ ចំពោះការចោទប្រកាន់ គឺមានភាពអយុត្តិធម៌ណាស់ចំពោះកូនក្តីខ្លួន ដែលពុំមានធាតុផ្សំសត្យានុម័តណាដែលបញ្ជាក់ថាកូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសទេ ។

សំណូមពរ៖ សូមតុលាការមេត្តា ពិនិត្យ និងពិចារណាឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ន បានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានចូលធ្វើការងារបានតែ ២ថ្ងៃ ដាក់ពាក្យតាមព័ត៌មានជូនដំណឹងតាមកាសែត និងទទួលបានប្រាក់ខែតិចតួច ។ នេះមានន័យថា ជនជាប់ចោទមិនបានដឹងអំពីអំពើល្មើសក្នុងក្លឹបផ្កាយ ដែលអាចកើតមានពីមុនទេ ។ កូនក្តីខ្លួនបានជាប់ចោទពីបទជួញដូរសារធាតុញៀន តាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទបានសារភាពនិងស្នើសុំសម្រាលទោស ដោយសារខ្លួនបានប្រព្រឹត្តលើកដំបូង មានជំងឺបេះដូងនិងបន្ទុកចិញ្ចឹមកូនអាយុ ១០ ឆ្នាំ (កូនពីរនាក់) និងម្តាយចាស់ជរា។ ជនជាប់ចោទបានសហការជាមួយសមត្ថកិច្ចដើម្បីឈានទៅរកមេក្លោងផ្សេងទៀត ។ សាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៥ ឆ្នាំ ។ ជនជាប់ចោទបានស្នើសុំបន្ធូរបន្ថយទោស ប៉ុន្តែសាលាឧទ្ធរណ៍ភ្នំពេញពុំបានផ្តល់ស្ថានសម្រាលឡើយ ។ តាមមាត្រា ៣២ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ផ្តល់សម្រាលទោសដល់អ្នកសមគំនិតដែលបានរាយការណ៍ឱ្យស្គាល់អត្តសញ្ញាអ្នកចូលរួមមុនពេលខ្លួនត្រូវបានចោទប្រកាន់ ត្រូវបន្ថយពាក់កណ្តាលនៃអតិបរមា និងពាក់កណ្តាលនៃអប្បបរិមា ក្នុងន័យនេះ ប្រសិនបើទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ១០ ឆ្នាំ ទោសផ្តល់សម្រាប់ស្ថានសម្រាលមានចន្លោះពី ២ ឆ្នាំ កន្លះ ទៅ៥ ឆ្នាំ ដែលតុលាការអាចសម្រេចក្នុងចន្លោះនេះ ។ សំអាងហេតុសាលាឧទ្ធរណ៍ភ្នំពេញគ្មានសំអាងហេតុត្រឹមត្រូវ ។

សំណូមពរ៖សូមប្រធានអង្គជំនុំជម្រះមេត្តាបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះសារជាថ្មី។

-ជនជាប់ចោទឈ្មោះ[redacted] យ៉ន បានឆ្លើយថា ខ្លួនសូមឯកភាពតាមមេធាវីការពារឱ្យខ្លួន ។

សំណូមពរ ខ្លួនមានជំងឺប្រចាំកាយដែលត្រូវព្យាបាល និងមានកូនស្រីតូចៗ និងម្តាយចាស់ជរាដែលត្រូវមើលថែ ។

-លោក [redacted] ចាន់ដារ៉ា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោ[redacted] ដារ៉ា បានធ្វើសេចក្តីសន្និដ្ឋានថា សូមឯកភាពតាមសហភាតារបស់ខ្លួន ។

-ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៧៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted]ដារី, លោក [redacted] ចាន់ដារ៉ា និងលោក[redacted]សីហា ជាមេធាវីការសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោ[redacted]ថាវរិន ក្នុងការប្តឹងសាទុក្ខ, បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោកស្រី [redacted]កនិកា ជាមេធាវីទទួល សិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ[redacted]ដារ៉ា ក្នុងការប្តឹងសាទុក្ខ , បណ្តឹងសាទុក្ខលេខ ៣៨៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted]យ៉ន និងបណ្តឹងសាទុក្ខលេខ ៤០២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់ លោក[redacted]ច័ន្ទតារាវុធ មេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ[redacted]តនា ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការនិងមាត្រា ៤១៧ ,មាត្រា ៤១៨ ,មាត្រា ៤២០ និងមាត្រា ៤២២ កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទឈ្មោះ[redacted]ដារ៉ា និងជនជាប់ចោទឈ្មោ[redacted]យ៉ន ក៏ដូចជាសេចក្តីថ្លែងការណ៍របស់លោកស្រីមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរនៅចំពោះមុខអង្គសវនាការនៅតុលាការកំពូលនេះថា ខ្លួនមិនសុខចិត្តនឹងការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដោយហេតុថាការផ្តន្ទាទោសខ្លួនមានលក្ខណៈធ្ងន់ធ្ងរពេក ដោយពុំបានពិចារណាទៅលើបញ្ញត្តិមាត្រា៩៣, មាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ការលើកឡើងអំពីអង្គច្បាប់ស្តីពីការផ្តល់នូវស្ថានសម្រាលដោយផ្អែកបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣២ និងមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គឺជាការពុំត្រឹមត្រូវទេ ដោយបញ្ញត្តិមាត្រា ៣៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានបញ្ញត្តថា *"បទប្បញ្ញត្តិនៃមាត្រា ៩៣ ដល់មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌមិនត្រូវយកមកអនុវត្តឡើយចំពោះបទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន"*។ រីឯការផ្តល់ជូននូវស្ថានសម្រាលតាមបញ្ញត្តិមាត្រា ៣២ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថា អំពើរបស់ជនជាប់ចោទទាំងពីរនាក់នេះពុំស្របទៅនឹងខ្លឹមសារនៃបញ្ញត្តិមាត្រានេះទេ ដោយ មាត្រា ៣២ បានបញ្ញត្តថា *"ក្នុងករណីចារី សហចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិតដែលបានរាយការណ៍ឱ្យស្គាល់អំពីអត្តសញ្ញាណអ្នកចូលរួមដទៃទៀត មុនពេលដែលខ្លួនត្រូវបានចោទប្រកាន់ ឬដែលបានជួយសម្រួលឱ្យមានការចាប់ខ្លួនជនដទៃទៀត ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់។"* ប៉ុន្តែ សកម្មភាពរបស់ជនជាប់ចោទពុំសមស្របទៅនឹងលក្ខខណ្ឌខាងលើនេះ ដែលគប្បីត្រូវទទួលបាននូវស្ថានសម្រាលឡើយ។

ម្យ៉ាងទៀត ការប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីរនាក់កន្លងមកនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ គឺបានឆ្លើយទទួលស្គាល់នូវអំពើរបស់ខ្លួនហើយ ដោយគ្រាន់តែសុំបន្ធូរបន្ថយទោសតែប៉ុណ្ណោះ ដូច្នេះ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍មកនេះត្រឹមត្រូវតាមច្បាប់ហើយ។



Scanned with CamScanner

៣-យល់ឃើញថា ការលើកឡើងរបស់លោក[redacted]ច័ន្ទតារាវុធ ក្នុងសារណាការពារ ក៏ដូចជាសេចក្ដីថ្លែងការណ៍នៅចំពោះមុខតុលាការកំពូលនេះថា "កូនក្ដីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ព្រោះកូនក្ដីខ្លួនមានភាពមមារញឹកជាមួយនឹងកិច្ចការផ្ទាល់ខ្លួនផ្សេងទៀត និងដោយសារមានការទុកចិត្តផង ក៏ប្រគល់ការគ្រប់គ្រងក្លឹបកម្សាន្តទាំងមូលឱ្យទៅបុគ្គលិករបស់គាត់ម្នាក់ដែលមានតួនាទីជាមេការនៃក្លឹបកម្សាន្តឱ្យមើលការខុសត្រូវនឹងចំណូលចំណាយទាំងមូល"។ការលើកឡើងនេះមិនត្រឹមត្រូវទេ ព្រោះក្នុងមុខរបរអាជីវកម្មបើកក្លឹប FLY នេះ គឺត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កូនក្ដីខ្លួនទាំងស្រុង គឺជនជាប់ចោទមិនអាចលើកនូវមូលហេតុនេះដើម្បីគេចផុតពីការទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌស្ដីពីអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនបានឡើយ។

៤-យល់ឃើញថា ការដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍សម្រេចផ្ដន្ទាទោសចំពោះជនជាប់ចោទឈ្មោះ[redacted] ថាវរិន ហៅ ទូច ដោយលើកសំអាងហេតុថា "នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted]ារី ឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ គឺដោយសារខ្លួនមិនបានប្រព្រឹត្តដូច ការចោទប្រកាន់។ ចំពោះចម្លើយរបស់ខ្លួននៅសមត្ថកិច្ច គឺខ្លួនបានផ្ដិតមេដៃ តែមិនបានអាន។ ចំពោះចម្លើយ របស់ឈ្មោះ [redacted]ដារ៉ា ខ្លួនសុំបដិសេធ។ ចម្លើយបដិសេធនេះ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញពុំអាចជឿជាក់បាន ព្រោះថា ជនជាប់ចោទបានឆ្លើយសារភាពនៅសមត្ថកិច្ចថា ក្នុងក្លឹបកំសាន្តផ្កាយ មានការជួញដូរគ្រឿងញៀន ហើយគ្រឿងញៀននោះ គឺឈ្មោះ រតនា កូនចៅរបស់ឈ្មោះ ទូច យកមកប្រគល់ឱ្យខ្លួនដល់ក្លឹប តែម្ដង។ លុះដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ខ្លួនបានប្រគល់គ្រឿងញៀនទៅឱ្យឈ្មោ[redacted]ម៉ែន គ្រប់គ្រងដើម្បីលក់បន្តពីខ្លួន ដែលចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់គ្នានឹងចម្លើយរបស់ឈ្មោះ [redacted]ម៉ែន និងឈ្មោះ[redacted]ដារ៉ា ព្រមទាំងកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាងចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ដែលអាចឱ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញជឿជាក់បានថា ជនជាប់ចោទពិតជាបានជួញដូរគ្រឿងញៀននៅក្នុងក្លឹបកំសានផ្កាយ ប្រាកដមែន" និងបានលើកបន្ថែមថា "នាពេលសវនាការ ជនជាប់ចោទឈ្មោះ[redacted]ថាវរិន ហៅ ទូច និងឈ្មោ[redacted]រតនា អវត្តមាន ។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ដារ៉ា និងឈ្មោះ[redacted]ម៉ែន និងចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted]ារី នៅសមត្ថកិច្ចឃើញថា ជនជាប់ចោទទាំងពីររូប គឺជាមេជួញដូរគ្រឿងញៀននៅក្នុងក្លឹបកំសាន្តផ្កាយ"។ នោះអង្គជំនុំជម្រះតុលាការកំពូលពិនិត្យពិចារណា ឃើញថា នៅពុំទាន់មានភាពច្បាស់លាស់នៅឡើយទេ បើយើងពិនិត្យទៅលើភស្តុតាងផ្សេងៗដូចជាលិខិតកិច្ចសន្យាជួលបន្តក្លឹបកំសាន្តផ្កាយ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ គឺក្លឹបកំសាន្ត គឺក្លឹបកំសាន្តនេះត្រូវបានជនជាប់ចោទឈ្មោះ[redacted]ថាវរិន បានជួលបន្តទៅឱ្យឈ្មោះ[redacted]រតនា ដោយមាន លោកមេធា[redacted] ថាន់ និងលោកមេធាវី[redacted]ដារ៉ា ប្រថាប់ត្រា ចុះហត្ថលេខា បានឃើញការព្រមព្រៀងនេះ នៅចំពោះមុខទៀតផង។ ហើយកិច្ចសន្យានេះមានលក្ខណៈស្របទៅនឹងការលើកឡើងរបស់លោកមេធាវីការពារ សិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ថាវរិន ដែលបានលើកឡើងនៅចំពោះមុខតុលាការកំពូលនេះថា កូនក្ដីរបស់ ខ្លួនក្រោយពីបានជួលទីតាំងក្លឹប FLY នេះទៅឱ្យឈ្មោះ[redacted]តនា រួច គឺកូនក្ដីខ្លួនបានចាកចេញទៅសហរដ្ឋអាមេរិក ចាប់តាំងពីពេលនោះ



Scanned with CamScanner

រហូតមកដល់បច្ចុប្បន្ននេះ មុនពេលដែលសមត្ថកិច្ចចុះបង្ក្រាបនៅទីតាំងក្លឹបកំសាន្ត FLY នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ មកម្ល៉េះ។

ហើយតាមសេចក្តីថ្លែងការណ៍របស់លោកមេធាវីការពារសិទ្ធិរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា កន្លងមក ទោះបីជាជនជាប់ចោទ [redacted] រតនា រត់គេចខ្លួន ក៏មេធាវីរបស់ឈ្មោះ [redacted] រតនា ទទួលស្គាល់ថា កូនក្តីខ្លួនពិតជាបានទទួលជួលទីតាំងក្លឹបកំសាន្ត FLY បន្តពីជនជាប់ចោទឈ្មោះ [redacted] ថាវរិន ពិតប្រាកដមែន។ លើសពីនេះទៅទៀត តាមរយៈដែលសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍លើកសំអាងហេតុត្រង់ចំណុចចម្លើយ ជនជាប់ចោទឈ្មោះ [redacted] ថារី ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា "ខ្លួនបានទទួលប្រាក់ខែចំនួន ៦០០$ ពីថៅកែក្លឹបកំសាន្ត FLY ឈ្មោះ [redacted] ថាវរិន ហៅ ទូច រហូតមក ។ ប៉ុន្តែ បើយើងពិនិត្យទៅលើកាលបរិច្ឆេទនៃកិច្ចសន្យាជួលទីតាំងទៅឱ្យឈ្មោះ [redacted] រតនា និងការអះអាងរបស់មេធាវីជនជាប់ចោទ [redacted] ថាវរិន គឺជនជាប់ចោទឈ្មោះ [redacted] ថាវរិន បានចេញទៅសហរដ្ឋអាមេរិកជាង ១ខែមុនមកហើយ ដែលចម្លើយនេះគប្បីសាលាឧទ្ធរណ៍ពិចារណាឡើងវិញ ដោយពិនិត្យផ្ទៀងផ្ទាត់ទៅនឹងភស្តុតាងផ្សេងៗ ដើម្បីស្វែងរកការពិត ស្របតាមបញ្ញត្តិមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោកស្រី [redacted] នីកា ជាមេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ក្នុងការប្តឹងសាទុក្ខ , បណ្តឹងសាទុក្ខលេខ ៣៨៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ប៉ុន និងបណ្តឹងសាទុក្ខលេខ ៤០២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ច័ន្ទតារាវុធ មេធាវីការពារសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] រតនា ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងមិនមានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៦-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៧៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោ [redacted] តារី, លោក ជា [redacted] រ៉ា និងលោក [redacted] សីហា មេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវរិន ក្នុងការប្តឹងសាទុក្ខ ធ្វើឡើងមានមូលហេតុនៃបណ្តឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII "ណ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ លើកលែងតែត្រង់ចំណុចនៃការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ថាវរិន គប្បីបដិសេធចោល និងបញ្ជូនទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិនិត្យ ពិចារណា សម្រេចឡើងវិញត្រង់ចំណុចបដិសេធស្របតាមសំអាងហេតុខាងលើ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

**១-បដិសេធ**បណ្តឹងសាទុក្ខលេខ ៣៧៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោកស្រី [redacted] នីកា ជា មេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ក្នុងការប្តឹងសាទុក្ខ , បណ្តឹងសាទុក្ខលេខ ៣៨៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ប៉ុន និងបណ្តឹងសាទុក្ខលេខ ៤០២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ច័ន្ទតារាវុធ មេធាវីការពារសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] រតនា ក្នុងការប្តឹងសាទុក្ខ។



Scanned with CamScanner

២-ទទួល បណ្ដឹងសាទុក្ខលេខ ៣៧៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់លោក [redacted] ធារី, លោក [redacted] ន់ដារ៉ា និងលោក [redacted] សីហា មេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ារវិន ក្នុងការប្ដឹងសាទុក្ខ ។

**៣-តម្កល់**សាលដីកាព្រហ្មទណ្ឌលេខ ៨០ ក្រII "ណ" ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី២ (ក) នៃសាលក្រមព្រហ្មទណ្ឌលេខ ១៤០៣ "ណក្រ៦" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បានសម្រេចតម្កល់ទុកជាបានការនោះត្រូវបដិសេធ និងបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ភ្នំពេញវិញ ដើម្បីជំនុំជម្រះសាជាថ្មីឡើងវិញ ត្រង់ចំណុចដែលបានបដិសេធ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២២។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ជាប្រធាន |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| ឯកឧត្ដម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

**បានឃើញ**

ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]

ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner